Diploma Programme
Programme du diplôme
Programa del Diploma

# Khmer A: literature – Standard level – Paper 1
# Khmer A : littérature – Niveau moyen – Épreuve 1
# Khmer A: literatura – Nivel medio – Prueba 1

Friday 8 May 2015 (afternoon)
Vendredi 8 mai 2015 (après-midi)
Viernes 8 de mayo de 2015 (tarde)

1 hour 30 minutes / 1 heure 30 minutes / 1 hora 30 minutos

### Instructions to candidates

- Do not open this examination paper until instructed to do so.
- Write a guided literary analysis on one passage only. In your answer you must address both of the guiding questions provided.
- The maximum mark for this examination paper is **[20 marks]**.

### Instructions destinées aux candidats

- N’ouvrez pas cette épreuve avant d’y être autorisé(e).
- Rédigez une analyse littéraire dirigée d’un seul des passages. Les deux questions d’orientation fournies doivent être traitées dans votre réponse.
- Le nombre maximum de points pour cette épreuve d’examen est de **[20 points]**.

### Instrucciones para los alumnos

- No abra esta prueba hasta que se lo autoricen.
- Escriba un análisis literario guiado sobre un solo pasaje. Debe abordar las dos preguntas de orientación en su respuesta.
- La puntuación máxima para esta prueba de examen es **[20 puntos]**.

2215 – 0567



© International Baccalaureate Organization 2015

International Baccalaureate®
Baccalauréat International
Bachillerato Internacional

https://xtremepape.rs/

សូមអ្នកធ្វើការវិភាគបែបអក្សរសិល្ប៍ទៅលើអត្ថបទ**មួយ**គត់។ ក្នុងចម្លើយរបស់អ្នក អ្នកត្រូវឆ្លើយតបនឹងសំណួរទាំងពីរដែលបានចោទសួរ។

**1.**

ស្តាប់សំដីអួតអាងសរសើររបស់ម្តាយធ្វើអោយនាងស្លុតស្មារតី ហាក់ដូចជាយកអ្វីមកចាក់ដោតចំបេះដូងរបស់នាងតែម្តង ។

-ម៉ាក់!... ចរិតរបស់ថៅកែនិងកូនគាត់ឫកខ្ពស់ណាស់ម៉ាក់!

-ណៃត!... កូនត្រូវដឹងថានៅក្នុងលោកនេះបើមានទ្រព្យសម្បត្តិ គឺមានអ្វីៗទាំងអស់មិនខ្វះទេកូន ។

-តែទ្រព្យសម្បត្តិដែលបានមកដោយមិនសមស្រប ក៏អាចនាំមនុស្សឱ្យវិនាសអន្តរាយប្រាសចាកសុភមង្គលច្រើនគ្នាណាស់ដែរម៉ាក់!

សម្តីអួតអាងរបស់ម្តាយរបស់នាងក៏តបវិញម្តងទៀត :

-កូនយល់ច្រឡំហើយ មិនដែលមានជនណាមួយដែលមានទ្រព្យសម្បត្តិហើយ ហើយត្រូវវេទនាដេកអោបទឹកភ្នែកនោះទេ!

-ចាស់! តែគ្រឿងនៃទ្រព្យហ្នឹងហើយ ដែលជាគ្រឿងបញ្ឆើចបញ្ឆើទាក់ទាញអារម្មណ៍លោភលន់របស់មនុស្សឱ្យវង្វេងភ្លើតភ្លើនក្នុងភាពសង្ហា ហើយប្រព្រឹត្តអំពើពាលអាវ៉ាសែ ធ្វើឱ្យសង្គមច្របូកច្របល់ ធ្វើឱ្យមនុស្សលែងស្គាល់មនុស្ស... ភ្លេចភ្លាំងអស់ហើយប្រពន្ធកូន... បំភ្លេចសូន្យឈឹងនូវគ្រាកំសត់ ទុរគត តោកយ៉ាកទឹកភ្នែកជូតក្បាលជង្គង់លើខ្នមរនាបបែកបាក់ក្រោមពន្លឺចាំងចូលតាមដំបូលស្លឹកធ្លុះធ្លាយ និងជញ្ជាំងរហែក... ។ ម៉ាក់!... ព្រោះតែដូច្នេះហើយបានជាកូនគិតថា ទ្រព្យសម្បត្តិមិនប្រសើរថ្លៃថ្លាជាងតម្រិះវិជ្ជា និងមនសិការស្នេហាជាតិមាតុភូមិនោះទេម៉ាក់!...

-ណៃត!... ម៉ាក់យល់ហើយសម្តីរបស់កូន!... តែកូនត្រូវដឹងថាទ្រព្យសម្បត្តិរបស់យើងសព្វថ្ងៃរីកចំរើនជាប្រចាំនេះ តើបានមកដោយសារអ្នកណា?

-ម៉ាក់!... នេះគឺពិតជាញើសឈាមរបស់ម៉ាក់រួមផ្សំនិងការវាងវៃ និងល្បិចកលផងទើបយើងអាចស្ទុះរហ័សដល់ម្លឹងនោះម៉ាក់!

-បើកូនយល់អញ្ចឹងដែរ កូនគួរតែយល់ពីបំណងរបស់ម៉ាក់ ដែលចង់និយាយអំពីអីហើយកូន...

ស្តាប់សម្តីម្តាយប្រាសមកវិញដូច្នេះ ផាណៃតក៏ពោលបន្ត :

-តែដូចកូនបានជម្រាបម៉ាក់អញ្ចឹងថា កូនមិនទាន់ចង់បានគ្រួសារទេម៉ាក់!

ឮសម្តីប្រកែករបស់កូន មីងយើងក៏ក្រោកឈរ ហើយពោលម្តងទៀតថា :

-តែម៉ាក់ត្រូវបង្ខំអោយកូនយក!... កូនរៀនប៉ុណ្ណឹងគ្រប់គ្រាន់ហើយ... កូនត្រូវតែរៀបការ... រៀបការជាមួយកូនថៅកែកោះកុងជាដាច់ខាត!

-ទេម៉ាក់! កូនសុំអង្វរ!... សូមម៉ាក់កុំបង្ខំអោយកូនរៀបការជាមួយកូនថៅកែអូ!... កូនគ្មានចិត្តស្រលាញ់ទេ!

-បើអញ្ចឹងមានតែឯងស្រលាញ់គ្រូសារ៉េត?

-ចាស៎! ចាស៎ម៉ាក់!...

គ្រាន់តែនាងពោលបញ្ចប់ស្ទើរតែមិនទាន់ ម្តាយនាងក៏យកដៃច្រត់ចង្កេះ ហើយពោលបន្តទៀតថា:

-មិនបាន!... មិនបានជាដាច់ខាត... ម៉ាក់មិនអោយឯងយកជ័រភ្នៅទៅត្បៀតភ្លៀកទេណៃត!... ។ កូនគិតមើលមើល៍!... តើគ្រូបង្រៀននិងប្រាក់ខែ អាចទិញម្សៅលាបមុខរបស់កូនបានមួយប្រអប់ទេ?... មួយថ្ងៃៗ មុខខ្មៅជាំ ស៊ីតែ

https://xtremepape.rs/

ជីស របេងរុំស្លួតស្វិតអស់ហើយពោះរកសាច់ឈាមភ្លឺថ្លានឹងគេគ្មានទេ... ដើរទៅណាមកណាឮតែឈ្មោះគ្រូបង្រៀន គេជួយអាណិតជួស ហើយស្តោះទឹកមាត់សើចចំអកពេបជ្រាយឱ្យពីក្រោយខ្នង... ។ នេះហើយចំណង់ចិត្ត ដែលកូនឯងចង់បាននោះឬ? នេះឬជាកិត្តិយសអនាគតកូន? ហ៊ឺ!... គួរឱ្យអស់សំណើចខ្លាំងណាស់នឹងភាពល្ងង់ខ្លៅឯងនេះណែត!

-ម៉ាក់!... កុំវាយតម្លៃបន្ថោកគាត់ខ្លាំងពេក ទោះគាត់មានប្រាក់ខែតិចមែនតែគាត់មានឧត្តមគតិស្នេហាជាតិខ្ពស់ ចេះជួយទុក្ខធុរៈមនុស្សដោយមិនប្រកាន់... ចេះច្នៃព្រលឹងមនុស្សជាច្រើនឱ្យក្លាយទៅជាមនុស្សដ៏ល្អរបស់សង្គម ។ មិនតែប៉ុណ្ណឹង គាត់ស្ម័គ្រចិត្តលះបង់អ្វីៗទាំងអស់ដើម្បីបុព្វហេតុការពារនិងកសាង មាតុភូមិដោយឥតស្តាយស្រណោះ ដែលផ្ទុយស្រឡះពីពពួកអ្នកមានដែលមិនហ៊ានទៅ ខំរកល្បិចកលគេចវេះពីភារកិច្ច... ខំជូលគេឯងអោយទៅជំនួសព្រោះខ្លាចការដ្ឋាន... ។ តើជនពីរជំពូកហ្នឹង តើជនណាដែលថោកទាបកំសាកគួរអោយខ្ពើមរអើមនោះ?....

ហ៊ឺ សុខៃ, *សន្ទើមធ្លាក់* (២០០៩)

(a) តាមរយៈអត្ថបទដកស្រង់ខាងលើ ចូរធ្វើការប្រៀបធៀបតួអង្គផាណែតនិងម្តាយរបស់នាង ។

(b) ចូរធ្វើការអត្ថាធិប្បាយទៅលើការប្រើភាសានៅក្នុងអត្ថបទដកស្រង់ខាងលើ ជាពិសេសទៅលើការមិនសូវប្រើមជ្ឈិមបុរិសៈ (ឯង លោក អ្នក) និងឧត្តមបុរិសៈ (ខ្ញុំ អញ យើង) ។



https://xtremepape.rs/

**2.**

**បរិស្ថាន**

- ធម្មជាតិខ្មែរធ្លាប់តែសម្បូរ    សម្បត្តិហៀរហូរច្រើនបំផុត
  បរិយាកាសបរិសុទ្ធ    ទន្លេសមុទ្រដីព្រៃភ្នំ ។
- មានសព្វសត្វបក្សីបក្សា    សត្វស្រុកមច្ឆារស់ជួបជុំ
  ម្រឹគីម្រឹគាមានទ្រនំ    រស់ក្នុងព្រៃធំដោយសុខសាន្ត ។
- តែឥឡូវត្រូវទទួលរង    គ្រោះកាចយង់ឃ្នងយ៉ាងសាមាន្យ
  បំផ្លាញគ្រប់ផ្នែកបរិស្ថាន    គ្មានលស់ស្រាកស្រាន្តរៀងរាល់ថ្ងៃ ។
- ការកាប់ដុតបំផ្លាញព្រៃឈើ    ប្រៀបដូចរុះរើនិងប្រល័យ
  ជំរំសត្វនិងរុក្ខជាតិខ្ស័យ    គ្រោះកាចចង្រៃកើតមាន ។
- ជួបគ្រោះរាំងស្ងួតខ្យល់ព្យុះភ្លៀង    រដូវលែងទៀងទាត់ទន្ទ្រាន
  ឱ្យយើងរស់រងគ្រោះអត់ឃ្លាន    គ្រោះអន្តរធានពីធម្មជាតិ ។
- មានព្រានប្រមាញ់បាញ់សត្វព្រៃ    ប្រើល្បិចកលលៃលកពិឃាត
  យកសាច់ឈាមស្បែកហូបហាលុះងៀត    ឆ្អឹងភ្លុកស្នែងទៀតគ្មានឈរឈប់ ។
- ឈ្មួញនេសាទត្រីប្រើរាល់ល្បិច    កម្ទេចបំផ្លិចបំផ្លាញគ្រប់
  ចាប់មច្ឆាជាតិទាំងថ្ងៃយប់    ប្រើមងអួនលប់ខ្សែភ្លើងឆក់ ។
- ជនពាលប្រើគ្រាប់បែកបោកត្រី    ថ្នាំពុលសេរីលបលួចឆ្មក់
  ធ្វើឱ្យវិនាសកកករល្អក់    ហុចផលអាក្រក់ផុតពូជខ្ទេច ។
- ចំណែកសត្វស្លាបគេតាមបាញ់    ប្រើលបសំណាញ់ទាក់គ្រញេច
  ប្រើថ្នាំពុលសម្លាប់កម្ទេច    សត្វមិនអាចគេចផុតធ្លាក់ព្រាន ។
- ពេលយកសាច់សត្វបរិភោគ    ជាតិពុលជ្រាបជោកសព្វកោះកៀន
  ជំងឺឈឺថ្កាត់នឹងកើតមាន    រោគាទន្ទ្រានអបលក្ខណ៍ ។
- ការប្រើប្រាស់សារធាតុគីមី    ដូចជាថ្នាំជីផ្សែងរោងចក្រ
  ចោលកាកសំណល់ពុលប្រត្យក្ស    បណ្តាលគ្រោះថ្នាក់មនុស្សសត្វ ។
- ដូច្នេះគួរការពារឱ្យបាន    ផ្នែកបរិស្ថានដោយប្រយ័ត្ន
  កុំបណ្តោយឱ្យបាត់បង់ខ្ចាត់    វែកមុខទប់ស្កាត់ព្រានធម្មជាតិ ។

ហានុមាន បូរិន្ទ, *គន្លឹះអភិវឌ្ឍន៍* (២០០២)

(a) តើអត្ថបទកំណាព្យដកស្រង់នេះចង់ផ្ញើសារអ្វីខ្លះអំពីបរិស្ថានដល់អ្នកអាន?

(b) ចូរធ្វើការអត្ថាធិប្បាយទៅលើការប្រើប្រាស់រូបភាព (*imagery*) នៅក្នុងអត្ថបទកំណាព្យដកស្រង់នេះ។ តើរូបភាពដែលកវីបានបង្កើតក្នុងកំនាព្យនេះជួយអ្នកឱ្យយល់នូវគំនិតចំបងរបស់កំណាព្យតាមរបៀបណាខ្លះ?

https://xtremepape.rs/